# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍សន្តយ៉ូសែប
# ជុំគីរី ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០
# ជាពេលវេលាដើម្បីប្រកាសដំណឹងល្អ

**អត្ថបទទី១៖ កិច្ចការ ២,១៤.២២ខ-៣៣**

ព្រះជាម្ចាស់បានប្រោសលោកយេស៊ូនេះឲ្យរស់ឡើងវិញ យើងខ្ញុំទាំងអស់គ្នាជាសាក្សី។ កក ២,៣២

**អត្ថបទទី២៖ ពេត្រុសទី១ ១,១៧-២១**

គឺដោយសារព្រះលោហិតដ៏ថ្លៃវិសេសរបស់ព្រះគ្រីស្ត* ដែលប្រៀបបាននឹងកូនចៀមដ៏ល្អឥតខ្ចោះ ឥតស្លាកស្នាម។ ១ពត្រ ១,១៩

**ដំណឹងល្អ៖ លូកា ២៤,១៣-៣៥**

ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «មនុស្សខ្វះប្រាជ្ញាអើយ! អ្នករាល់គ្នាមិនងាយជឿពាក្យទាំងប៉ុន្មានដែលពួកព្យាការីបានថ្លែងសោះ»។លក ២៤,២៥

បងប្អូនជាទីស្រឡាញ់!

មួយខែកន្លងមក យើងថ្វាយអភិបូជាឆ្ងាយពីគ្នាតែដោយមានចិត្តគំនិតតែមួយ **តើឥតមានភ្លើងដែលកំពុងឆេះនៅក្នុងដួងចិត្តរបស់យើង? តើឥតមានភ្លើងមួយដែលណែនាំឲ្យយើងមានអារម្មណ៍ថាយើងរំភើប?** មិនមែនជាភ្លើងដែលណែនាំឲ្យយើងពិបាកចិត្ត យើងអន់ចិត្ត មិនមែនជាភ្លើងដែលយើងពិបាកចិត្តដោយសារយើងឥតមានឱកាសថ្វាយអភិបូជារួមជាមួយគ្នា។ មិនមែនដោយសារយើងឈឺចិត្តពេលឃើញមានមនុស្សយ៉ាងច្រើនកំពុងស្លាប់នៅក្នុងពិភពលោក យើងកំពុងព្រួយបារម្ភអំពីឥទ្ធិពលអាក្រក់ទាំងនៅលើពិភពលោក ទាំងនៅប្រទេសកម្ពុជា ដោយសារជំងឺកូវីដ១៩។ ប៉ុន្តែ ខ្ញុំគិតថាដួងចិត្តរបស់ខ្ញុំ បេះដូងរបស់ខ្ញុំ ក៏ដូចជាបេះដូងរបស់បងប្អូន កំពុងឆេះយ៉ាងខ្លាំងនៅពេលស្តាប់ព្រះបន្ទូលដំណឹងល្អ នៅពេលស្តាប់កិច្ចការគ្រីស្តទូតពេញមួយសប្តាហ៍កន្លងមក។ ម្សិលមិញ យើងគោរពសន្តម៉ាកុសដែលជាអ្នកនិពន្ធដំណឹងល្អ ព្រឹកនេះយើងបានស្តាប់លោកសិលា ដែលកំពុងប្រកាសដល់ប្រជាជននៅទីក្រុងយេរូសាឡឹមថា "**ព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញពិតមែន**"។ ជាពិសេស ពេលយើងស្តាប់ព្រះយេស៊ូដែលបកស្រាយព្រះបន្ទូលរបស់ព្រះអង្គដល់សាវ័កពីរនាក់ដែលធ្វើដំណើរជាមួយព្រះអង្គ។

ថ្ងៃនេះ ខ្ញុំចង់និយាយយ៉ាងច្បាស់ថា ទោះបីមានកូវីដ១៩ឬគ្មានកូវីដ១៩ក៏ដោយ នេះជាពេលវេលាដើម្បីប្រកាសដំណឹងល្អ ជាពេលវេលាដែលយើងជាគ្រីស្តបរិស័ទបញ្ចេញសកម្មភាពដ៏កំពូល។ មិនមែនជាពេលវេលាដើម្បីឲ្យយើងទៅជាមនុស្សខ្ជិល មិនមែនជាពេលវេលាដើម្បីឲ្យ

យើងអស់កម្លាំង មិនមែនជាពេលវេលាដើម្បីឲ្យយើងបាត់បង់សេចក្តីសង្ឃឹម ទោះបីមានកូវីដ១៩ ឬគ្មាន ជាពេលវេលាដើម្បីប្រកាសដំណឹងល្អ។ សូមបើកភ្នែក សូមបើកត្រចៀក សូមបើកដួងចិត្ត ជាពិសេសសូមមើលលោកសិលានិងលោកយ៉ូហានកន្លងមក នៅពេលលោកទាំងពីរទៅវិហារ នៅទីក្រុងយេរ៉ូសាឡឹមគាត់បានឃើញអ្នកសុំទានម្នាក់ដែលពិការជើង នៅពេលនោះគាត់ថា "**សុំទោសលុយយើងឥតមាន ប្រាក់ក៏យើងគ្មានដែរ ប៉ុន្តែអ្វីដែលយើងមានយើងសូមជូនដោយអំណរសប្បាយ គឺដោយនាមព្រះយេស៊ូគ្រីស្ត សូមឈរឡើងនឹងដើរទៅ**"។ ដោយសារគេបាននិយាយដូចនេះ លោកសិលានិងលោកយ៉ូហានក៏ដូចជាក្រុមគ្រីស្តទូតឯទៀតៗ គឺនឹងត្រូវគេចាប់កាត់ក្តី ប៉ុន្តែចុងក្រោយអ្នកដែលចាប់ក្រុមគ្រីស្តទូតទាំងនោះ រកមិនឃើញមូលហេតុដើម្បីដាក់ទោសដល់ក្រុមគ្រីស្តទូត។ ដូច្នេះ គេបានទុកឲ្យក្រុមគ្រីស្តទូតបន្តធ្វើដំណើរដោយកាត់បន្ថយសិទ្ធិសេរីភាពរបស់ក្រុមគ្រីស្តទូត។ ប៉ុន្តែ ក្រុមគ្រីស្តទូតគេបានបន្តទៅប្រកាសដំណឹងល្អនៅក្នុងធម្មសាលា និងជាពិសេសនៅតាមផ្ទះដើម្បីប្រកាសអំពីព្រះយេស៊ូដែលជាព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅសព្វថ្ងៃ។

លោកសិលាដែលនៅជាមួយក្រុមគ្រីស្តទូតក្នុងបន្ទប់យ៉ាងតូច ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកណែនាំឲ្យគេមានសេចក្តីក្លាហាន គេហ៊ានចេញពីបន្ទប់នោះទៅទីក្រុងយេរ៉ូសាឡឹមដើម្បីប្រកាសអំពីព្រះយេស៊ូគ្រីស្ត។ នៅពេលនោះ គេគ្មានសៀវភៅដើម្បីអប់រំជំនឿទេ គឺគេមានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលនោះលោកសិលាដូចជាបាននិទានព្រះបន្ទូលរបស់ព្រះជាម្ចាស់សាជាថ្មី ដោយពាក្យរបស់គាត់ផ្ទាល់ ដោយនឹករលឹកព្រះបន្ទូលរបស់ព្រះយេស៊ូ ដោយនឹករលឹកជីវិតរបស់ព្រះអង្គ គេនិទានរឿងព្រះយេស៊ូដើម្បីឲ្យមហាជនស្តាប់លឺ។ ថ្ងៃនេះ យើងឃើញព្រះយេស៊ូដែលកំពុងធ្វើដំណើរជាមួយលោកសិលានិងលោកយ៉ូហាន ពីទីក្រុងយេរ៉ូសាឡឹមទៅភូមិអេម៉ាអូសដែលមានចម្ងាយប្រហែល១១គីឡូម៉ែត្រ។ ទាំងពីរនាក់គេកំពុងពិបាកចិត្តកំពុងអស់សង្ឃឹម គេពោរពេញដោយសេចក្តីសង្ឃឹមដោសារព្រះយេស៊ូ តែពេលនេះព្រះយេស៊ូសោយទិវង្គត។ ប៉ុន្តែ ព្រះយេស៊ូបានគង់នៅជាមួយគេ ធ្វើដំណើរជាមួយគេ គេមើលព្រះអង្គមិនស្គាល់ ពេលនោះព្រះយេស៊ូបានអានសាជាថ្មី បានបកស្រាយសម្ពន្ធមេត្រីចាស់ ព្រះបន្ទូលនីមួយៗដែលទាក់ទងនឹងព្រះអង្គពីដើម ដើម្បីបើកចិត្តគំនិតរបស់គេ។ នៅពេលនោះ គេនៅតែមិនទាន់មើលឃើញ គេនៅទន្ទឹងរង់ចាំពេលវេលាដែលព្រះយេស៊ូយកនំប៉័ងមកកាច់ នៅពេលនោះបាត់ព្រះយេស៊ូហើយ ប៉ុន្តែណែនាំឲ្យគេយល់ថានេះជាព្រះយេស៊ូ ដែលគង់នៅជាមួយយើង។ យើងបានធ្វើដំណើរជាមួយព្រះអង្គ១១គីឡូម៉ែត្រ នៅពេលនោះហើយបេះដូងរបស់គេកំពុងរំភើប កំពុងឆេះដូចភ្លើងដោយសារគេបានស្តាប់ព្រះបន្ទូលព្រះយេស៊ូផ្ទាល់។

ដោយសារ ម៉ាកុស លូកា ម៉ាថាយ យ៉ូហាន យើងមានព្រះបន្ទូលរបស់ព្រះយេស៊ូផ្ទាល់សព្វថ្ងៃ ពីសម័យដើមគ្មានសៀវភៅដើម្បីអប់រំជំនឿ។ គេនឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូ ហើយគេបានកត់ត្រាព្រះបន្ទូលដែលគេនឹកឃើញ ណែនាំឲ្យសព្វថ្ងៃយើងមានគម្ពីរដំណឹងល្អ ដែលយើងស្តាប់ជារៀងរាល់ថ្ងៃ ដើម្បីបំភ្លឺជីវិតរបស់យើង។ យើងចាំថា ព្រះបន្ទូលចុងក្រោយ ដែលមាននៅក្នុងអត្ថបទគម្ពីរដែលតែងដោយសន្តម៉ាកុសគឺ "**សូមទៅប្រកាសដំណឹងល្អ សូមធ្វើពិធីជ្រមុជទឹកឲ្យគេ សូមលើកលែងទោសឲ្យគេ សូមព្យាបាលអ្នកជំងឺឲ្យគេបានជាសះស្បើយ**" នៅពេលនោះ ព្រះយេស៊ូកំពុងធ្វើការជាមួយពួកគេ ព្រះអង្គបានបង្ហាញអំពីព្រះបន្ទូលយ៉ាងជាក់ស្តែង ដោយមានសញ្ញាសម្គាល់ឲ្យគេមើលឃើញពិតមែន ព្រះបន្ទូលរបស់ព្រះអង្គគង់នៅជាមួយគេ។ ព្រះវិញ្ញាណដ៏វិសុទ្ធកំពុងសណ្ឋិតលើយើង ណែនាំឲ្យយើងលែងភ័យខ្លាចដើម្បីប្រកាសដំណឹងល្អតទៅទៀត យើងមិនខ្លាចដើម្បីធ្វើជាសាក្សីនៃព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញ។ ពិតមែន យើងធ្វើ យើងអនុវត្តតាមសេចក្តីណែនាំពីរដ្ឋាភិបាល ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ យើងបានបិទសាលារៀនរបស់ព្រះសហគមន៍កាតូលិកយើងទាំងអស់ យើងលែងជួបជុំគ្នាបែបសាសនា។ ប៉ុន្តែ យើងដឹងថាយើងមានសិទ្ធិដើម្បីអធិដ្ឋាន ឲ្យយើងយកចិត្តទុកដាក់ដើម្បីភ្ញាក់ស្មារតី ដោយមានអនាម័យយ៉ាងច្បាស់ ដោយខិតខំរក្សាគម្លាតពីគ្នា ដោយកាត់បន្ថយការធ្វើដំណើរ...។ យើងអរព្រះគុណព្រះជាម្ចាស់ ដែលប៉ុន្មានថ្ងៃចុងក្រោយនេះគ្មានករណីឆ្លងជំងឺកូវីដ១៩នេះទៀត ដោយដឹងថាមានអ្នកជំងឺកូវីដ១៩នៅប្រទេសកម្ពុជាយើងមានជាង៩៥% បានជាសះស្បើយ។

ខ្ញុំសូមស្នើដល់លោកបូជាចារ្យទាំងអស់ ដល់បព្វជិតបព្វជីតា ដល់គ្រីស្តបរិស័ទយើងទាំងអស់នៅក្នុងភូមិភាគភ្នំពេញ ក៏ដូចជានៅក្នុងព្រះសហគមន៍កាតូលិកកម្ពុជាទាំងមូល បន្តភ្ញាក់ស្មារតី បន្តយកចិត្តទុកដាក់ បន្តប្រុងប្រយ័ត្ន បន្តស្តាប់និងអនុវត្តតាមសេចក្តីណែនាំរបស់រដ្ឋាភិបាល ដោយដឹងថាអាចមានករណីទីពីរដែរ។ ទោះបីយើងមានបញ្ហាជំងឺកូវីដ១៩នេះ យើងដឹងថា ព្រះបន្ទូលរបស់ព្រះយេស៊ូកំពុងណែនាំឲ្យយើងបង្កើតភ្លើងមួយនៅក្នុងដួងចិត្ត ភ្លើងនេះកំពុងណែនាំឲ្យជីវិតរបស់យើង វិញ្ញាណរបស់យើងកំពុងឆេះឡើងដោយនាមព្រះយេស៊ូ។ នេះជាពេលវេលាដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីចែករំលែកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីបម្រើបងប្អូនរបស់យើងអស់ពីសមត្ថភាព។ ហេតុនេះហើយ ព្រឹកនេះខ្ញុំសូមអញ្ជើញគ្រីស្តបរិស័ទម្នាក់ៗ គ្រូអប់រំជំនឿម្នាក់ៗ ឪពុកម្តាយធម៌ម្នាក់ៗ ដើម្បីភ្ញាក់ស្មារតីនឹងយកចិត្តទុកដាក់ដើម្បីធ្វើជាគ្រីស្តទូតមួយយ៉ាងសកម្មបំផុត ដើម្បីបំពេញតួនាទីរបស់យើងជាគ្រីស្តទូតអស់ពីដួងចិត្ត អស់ពីស្មារតី អស់ពីជំនឿ អស់ពីសេចក្តីស្រឡាញ់។

ពីសម័យដើម ក្រុមគ្រីស្តបរិស័ទគេធ្លាប់ធ្វើអ្វីខ្លះ? អធិដ្ឋាន ស្តាប់ការអប់រំរបស់ក្រុមគ្រីស្តទូត (មានន័យថាស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ និងស្តាប់ជីវិតរបស់ព្រះយេស៊ូ) និងបម្រើបងប្អូនឯទៀតៗ។ ដូច្នេះ នៅក្នុងភូមិភាគភ្នំពេញទាំងមូល ឲ្យយើងឈរឡើងដើម្បីនៅក្នុងសប្តាហ៍នេះយើងទៅជួបជាមួយបងប្អូនដែលទទួលការអប់រំជំនឿ ជំហានទីមួយ ជំហានទីពីរ (ដែលមិនបានទាន់បានទទួលអគ្គសញ្ញាជ្រមុជទឹកកន្លងមក) យុវជនយុវនារី កូនក្មេងដែលធ្លាប់ចូលនៅក្នុងព្រះសហគមន៍ពីមុន គ្រីស្តបរិស័ទរបស់យើងដែលជាអ្នកជិតខាង ដែលគ្មានសមត្ថភាពដើម្បីចូលរួមអធិដ្ឋានឬអភិបូជាតាមអ៊ីនធើណេត គ្រីស្តបរិស័ទមួយចំនួនដែលមិនចេះអានព្រះបន្ទូលរបស់ព្រះជាម្ចាស់។ សូមគ្រូអប់រំជំនឿ សូមឪពុកម្តាយធម៌ សូមគ្រីស្តបរិស័ទ ទៅតាមផ្ទះអ្នកជិតខាងរបស់យើងដើម្បីអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីនិទានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីណែនាំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់បំភ្លឺជីវិតរបស់បងប្អូនយើងទាំងនោះ។ រួមគ្នាយើងអង្គុយដើម្បីសួរសុខទុក្ខគ្នា ដើម្បីយល់អំពីទុក្ខលំបាក ដើម្បីមើលឥទ្ធិពលអាក្រក់ទៅលើជីវិតបងប្អូនយើងដោយសារជំងឺកូវីដ១៩នេះ។

លោកឪពុកជាទីស្រឡាញ់ បព្វជិតបព្វជិតាជាទីស្រឡាញ់ គ្រីស្តបរិស័ទដែលបានផ្ញើជីវិតទៅលើព្រះជាម្ចាស់ជាទីស្រឡាញ់ គ្រូអប់រំជំនឿជាទីស្រឡាញ់ សូមរៀបចំក្រុមគ្រីស្តទូតជាបន្ទាន់ឲ្យយើងមានកងទ័ពរបស់ព្រះជាម្ចាស់ ដែលចេញពីគ្រប់ទីកន្លែង។ នៅកន្លែងដែលយើងនៅ ខ្ញុំមិនចង់ឃើញបងប្អូនដែលទទួលការអប់រំជំនឿ ជំហានទីមួយ ជំហានទីពីរ យុវជនយុវនារី កូនក្មេងដែលធ្លាប់ចូលនៅក្នុងព្រះសហគមន៍ពីមុន គ្រីស្តបរិស័ទដែលគ្មានសមត្ថភាពដើម្បីចូលរួមអធិដ្ឋានឬអភិបូជាតាមអ៊ីនធើណេត និងគ្រីស្តបរិស័ទដែលមិនចេះអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ត្រូវបានយើងមើលរំលងឬភ្លេចបងប្អូនណាម្នាក់ឡើយ។ នៅគ្រប់ទីកន្លែង យើងផ្ញើអត្ថបទព្រះបន្ទូលសម្រាប់ពេញមួយសប្តាហ៍ សូមព្រីន សូមថតចម្លង និងចែកដល់បងប្អូនជាក្រុមគ្រីស្តទូតរបស់យើងដែលយើងនឹងតែងតាំង ដើម្បីឲ្យគេទៅតាមផ្ទះដែលមានអ្នកទទួលការអប់រំជំនឿ ផ្ទះដែលមានយុវជនយើងដែលមិនអាចចូលព្រះវិហារបានសព្វថ្ងៃ ផ្ទះដែលមានបងប្អូនដែលមិនចេះអានព្រះបន្ទូល ឬគ្មានមធ្យោបាយដើម្បីចូលរួមអធិដ្ឋាននិងអភិបូជាតាមអ៊ីនធើណេត កុំឲ្យយើងភ្លេចផ្ទះណាមួយ។

នៅក្នុងភូមិភាគភ្នំពេញយើងមាន៥០ព្រះសហគមន៍ ដែលមានព្រះសហគមន៍មួយចំនួនតូចដែលមានគ្រីស្តបរិស័ទតិច មានអ្នកទទួលការអប់រំជំនឿតិច មានយុវជនតិច ហេតុនេះហើយយើងអាចធ្វើបានដោយមិនភ្លេចអ្នកណាសោះ។ ប្រសិនបើយើងខិតខំរៀបចំដោយឆន្ទៈ ដែលពោរពេញដោយសេចក្តីស្រឡាញ់ ខ្ញុំជឿថាក្រុមគ្រីស្តទូតរបស់យើងក្នុងភូមិភាគភ្នំពេញ អាច

ប្រកាសដំណឹងល្អដោយដឹងថា ពិតមែនព្រះពន្លឺរបស់ព្រះអង្គ ភ្លើងរបស់ព្រះអង្គកំពុងឆេះនៅក្នុងដួងចិត្តរបស់យើង ព្រះយេស៊ូគង់នៅជាមួយយើងដើម្បីបញ្ជាក់សញ្ញាសម្គាល់ថែមទៀត។ ប៉ុន្មានថ្ងៃមុន ខ្ញុំបានសុំឲ្យព្រះសហគមន៍នីមួយៗចាប់ផ្តើមមានសញ្ញាអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ យើងបានបង្កើតក្រុមមួយនៅក្នុងតេឡេក្រាម (Telegram) ដែលយើងអាចបញ្ចូលទាំងស្នាដៃរបស់យើង យើងអាចចូលមើលដើម្បីទទួលយកយោបល់ថ្មីៗ ឲ្យយើងមានសកម្មភាពតាមកន្លែងនីមួយៗ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ចេញសញ្ញាសម្គាល់យ៉ាងជាក់ស្តែង។

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ខាងមុខនេះ ពេលព្រឹកខ្ញុំនឹងប្រជុំជាមួយប្រធានការិយាល័យនីមួយៗនៅក្នុងភូមិភាគភ្នំពេញ។ ពេលរសៀល ខ្ញុំនឹងប្រជុំជាមួយអង្គការកាតូលិកយើងទាំងអស់ ដើម្បីឲ្យយើងគិត តើព្រះយេស៊ូដែលគង់នៅជាមួយយើងអាចធ្វើអ្វីខ្លះរួមជាមួយយើង ដើម្បីបង្ហាញយ៉ាងជាក់ស្តែងតាមសញ្ញានៃធម៌មេត្តាករុណា អំពីវត្តមានរបស់ព្រះអង្គនៅក្នុងសង្គមយើងបច្ចុប្បន្ននេះ។ កុំគិតវែងឆ្ងាយពេក ប៉ុន្មានថ្ងៃមុនខ្ញុំបានទៅសួរសុខទុក្ខចៅអធិការវត្តអង្គមន្ត្រី ខ្ញុំបាននិយាយទៅចៅអធិការវត្តថា "**ដល់ពេលវេលាដែលយើងសហការគ្នានៅក្នុងរបៀបថ្មី**"។ នៅក្នុងបរិវេណវត្ត យើងឃើញមានសល់ដីទំនេរយ៉ាងធំ ជាពេលវេលាដើម្បីឲ្យយើងចាប់ផ្តើមរៀបចំសួនបន្លែធម្មជាតិ រួមជាមួយព្រះសង្ឃ កូននេន ពុទ្ធបរិស័ទ សាលាវិទ្យាល័យបច្ចេកទេសឯកជនសន្តប្រាំងស្វ័រ ព្រះសហគមន៍កាតូលិក ឲ្យយើងដាំបន្លែជួយព្រះសង្ឃឲ្យមានបន្លែធម្មជាតិ និងជួយដល់ពុទ្ធបរិស័ទដែលបន្តិចទៀតអាចនឹងមានទុក្ខលំបាកយ៉ាងខ្លាំង ដោយសារបាត់បង់ការងារ បាត់បង់ចំណូលប្រចាំ ចៅអធិការវត្តបានឯកភាព សប្តាហ៍ក្រោយយើងនឹងចាប់ផ្តើម។ ដូច្នេះ កុំឲ្យយើងគិតអ្វីដែលធំៗតែឲ្យយើងគិតនៅក្នុងរបៀបតូចតាចដែលយើងអាចធ្វើបាន។ ប៉ុន្មានសប្តាហ៍មុន យើងអាចឃើញផ្ទាល់ភ្នែកនៅព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច បានចាប់ផ្តើមសហការជាមួយអាជ្ញាធរដីដើម្បីជួយអ្នកក្រីក្រ កន្លែងបងស្រីមេត្តាករុណាបានទៅសួរសុខទុក្ខអ្នកក្រីក្របំផុតនៅក្នុងរាជធានីភ្នំពេញ។ ខ្ញុំបានឃើញម្នាក់ៗមានសមត្ថភាពតាមរបៀបផ្ទាល់ខ្លួន ខ្ញុំក៏បានឃើញរូបថតកូនក្មេងនៅក្នុងមណ្ឌលបងស្រីមេត្តាករុណា ដែលកំពុងធ្វើជាគ្រូអប់រំបង្រៀនភាសាខ្មែរដល់បងស្រី។ គាត់ជាអ្នកជំងឺតូចតាច គាត់មានពេលទំនេរមានកម្លាំងគាត់បានយកចិត្តទុកដាក់ ដើម្បីចែករំលែកចំណេះដឹងរបស់គាត់ដោយបង្រៀនភាសាខ្មែរដល់បងស្រី។

ថ្ងៃនេះ ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ ជាពិសេសគ្រីស្តបរិស័ទ គ្រូអប់រំជំនឿ ឪពុកម្តាយធម៌ ចុះឈ្មោះតាមរយៈលោកឪពុកនៅកន្លែងនីមួយៗ ដើម្បីទៅជាក្រុមគ្រីស្តទូតដែលនឹងទៅប្រកាសដំណឹងល្អតាមផ្ទះអ្នកដែលបានទទួលការអប់រំជំនឿ ឬបងប្អូនដែលឥតមានអ៊ីនធើណេត និងអ្នកដែលមិនចេះអានអក្សរ។ យើងធ្វើសម្រាប់សាលាមត្តេយ្យបាន យើងធ្វើសម្រាប់គ្រីស្ត

បរិស័ទយើងបាន ដូច្នេះខ្ញុំនឹងផ្ញើអត្ថបទឲ្យកន្លែងនីមួយៗព្រីន ថតចម្លង ហើយក្រុមគ្រីស្តទូតមកទទួលដើម្បីទៅចែកតាមផ្ទះ និងអង្គុយជាមួយគេយ៉ាងតិចមួយម៉ោងក្នុងមួយសប្តាហ៍។ ជាមួយអ្នកជិតខាង យើងអង្គុយដោយរក្សាគម្លាតពីគ្នា ដោយមានអនាម័យ ដើម្បីរក្សាសុខភាពរបស់យើងទាំងអស់គ្នា។ ពិតមែន ខ្ញុំជឿថាភ្លើងកំពុងឆេះនៅក្នុងភូមិភាគភ្នំពេញទាំងមូល រួមគ្នាយើងដើរឆ្ពោះទៅជីវិត ឆ្ពោះទៅសេចក្តីសុខសាន្តរួមជាមួយព្រះយេស៊ូដែលគង់នៅជាមួយយើង។ អាម៉ែន៕ អាលេលូយ៉ា៕